- ដោយផ្អែកការចាំបាច់នូវការអភិវឌ្ឍន៍តំបន់ជ្រោយចង្វារ

**សម្រេច**

**មាត្រា១.-** បង្កើតតំបន់អភិវឌ្ឍន៍ជ្រោយចង្វារលើផ្ទៃដីទំហំ ៤៥០ហិកតានិងមានទីតាំង ស្ថិតនៅចន្លោះផ្លូវជាតិ លេខ ៦អានិងដងទន្លេសាបចាប់ពីគល់ស្ពានជ្រោយចង្វារត្រើយខាង កើត ទៅទិសខាងជើង (ដូចមានផែន ទីភ្ជាប់ ជាមួយ) ។

**មាត្រា២.-** ដីដែលស្ថិតនៅសងខាងគល់ស្ពានជ្រោយចង្វារចំងាយ១០០ម៉ែត្រ អមសងខាងផ្លូវជាតិ លេខ ៦អា ទៅទល់នឹងរង្វង់មូល ត្រូវទុកអោយនៅទំនេរដោយមិនអោយមានសំណង់អ្វីឡើយ ។

**មាត្រា៣.-** ដីក្នុងរង្វង់មូលខាងកើតគល់ស្ពានជ្រោយចង្វារក្នុងរង្វង់កាំចំងាយ១៥០ម៉ែត្រ ត្រូវរក្សាទុកអោយនៅទំនេរមិនឱ្យមានសំណង់អ្វីឡើយ ។

**មាត្រា៤.-** បណ្តាសំណង់ លំនៅដ្ឋាន ដីធ្លីដែលបានកាន់កាប់កន្លងមកហើយស្ថិតក្នុងតំបន់អភិវឌ្ឍន៍ នេះ រដ្ឋនឹង កំណត់គោលនយោបាយដោះស្រាយ ។

**មាត្រា៥.-** ហាមការជីក និងចាក់បំពេញ ហាមការសាងសង់ថ្មី ការសាងសង់បន្ថែម ការលក់ទិញការផ្ទេរសិទ្ធិ ទាំងអស់នៅក្នុងតំបន់ខាងលើក្រោយពីថ្ងៃចេញអនុក្រឹត្យនេះរហូតដល់មានប្លង់ប្រើប្រាស់ដីធ្លី ។

**មាត្រា៦.-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងសាធារណការនិងដឹកជញ្ជូនក្រុមប្រឹក្សាអ្នកច្បាប់សាលាក្រុងភ្នំ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

---

## អនុក្រឹត្យលេខ ៣៤ អ.ន.ក្រ.បក

## ស្តីពីការ

## ចេញផ្សាយក្រដាសប្រាក់

## ប្រភេទ ៥០០០រៀល, ១០.០០០រៀល, និង ៥០.០០០រៀល គំរូថ្មី

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករាឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិនៃធនាគារជាតិនៃកម្ពុជា
- តាមសំណើរបស់អគ្គទេសាភិបាលធនាគាជាតិកម្ពុជា ។

**សំរេច**

**មាត្រា១.**_ អនុញ្ញាតឱ្យចេញផ្សាយ ធ្វើចរាចរនិងប្រើប្រាស់ក្នុងទូទាំងព្រះរាជានាចក្រកម្ពុជា នូវក្រដាសប្រាក់ ៥ ០០០រៀល- ១០.០០០រៀល និង ៥០.០០០រៀល គំរូថ្មី ទន្ទឹម និងប្រភេទប្រាក់ដែល មាន ចេញផ្សាយរួចមក់ហើយ ។

**មាត្រា២.**_ធនាគារជាតិនៃកម្ពុជា មានភារកិច្ចចេញសេចក្តីប្រកាសមួយដើម្បីផ្សព្វផ្សាយពីលក្ខណៈ សំគាល់នៃក្រដាសប្រាក់គំរូថ្មីនេះ ។

**មាត្រា៣.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្ត -ក្រុងត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ៣៥ អ.ន.ក្រ.បក**

**ស្តីពី**

**ការផ្តល់ប្រាក់បំណាច់បន្ថែមលើបៀវត្សប្រចាំខែ សំរាប់នាយក នាយកដ្ឋាន ប្រធានស្ថាប័នឯករាជ ចំណុះផ្ទាល់ក្រសួងការពារជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា